**NEWS RELEASE**

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# ជំងឺកូវីដ១៩៖ អ្នកស្រី បាស្លេទ្បេត បានមានប្រសាសន៍ថា វិធានការពិសេស មិនគួរត្រូវបានអនុវត្ត ដើម្បីបិទបាំងអំពើរំលោភបំពានសិទ្ធិមនុស្សឡើយ

ទីក្រុងហ្សឺណែវ (២៧ មេសា ២០២០) - នៅពេលដែលរដ្ឋាភិបាលទាំងឡាយជួបប្រទះនឹងបញ្ហាគួរឱ្យភ័យខ្លាចក្នុងការការពារប្រជាជនពីជំងឺកូវីដ-១៩ ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស អ្នកស្រី មីស៊ែល បាស្លេទ្បេត បានអំពាវនាវឱ្យរដ្ឋទាំងអស់ ធានាថា សិទ្ធិមនុស្សមិនត្រូវបានរំលោភបំពានក្រោមវិធានការពិសេស ឬវិធានការគ្រាអាសន្នឡើយ។

អ្នកស្រី បាស្លេទ្បេត បានព្រមានថា៖ “អំណាចពេលគ្រាអាសន្ន មិនគួរជាអាវុធដែលរដ្ឋាភិបាលជាច្រើន អាចយកមកប្រើប្រាស់ ដើម្បីបង្ក្រាបមតិប្រឆាំង គ្រប់គ្រងប្រជាជន ហើយសូម្បីតែដើម្បីបន្តពេលវេលាកាន់អំណាចរបស់ពួកគេ នោះទេ”។ “អំណាចគួរតែត្រូវបានប្រើប្រាស់ ដើម្បីទប់ទល់នឹងរោគរាតត្បាតប្រកបដោយប្រសិទ្ធភាព – មិនលើសពីនេះ មិនតិចជាងនេះ”។

រដ្ឋអាចរឹតត្បិតសិទ្ធិមួយចំនួន ដើម្បីការពារសុខភាពសាធារណៈក្រោមច្បាប់សិទ្ធិមនុស្ស ហើយក៏មានអំណាចបន្ថែមទៀតផងដែរ ប្រសិនបើស្ថានភាពគ្រាអាសន្នគំរាមកំហែងដល់អាយុជីវិតរបស់ប្រទេសជាតិត្រូវបានប្រកាសជាសាធារណៈ។ ក្នុងករណីណាមួយនេះ ការរឹតត្បិតត្រូវតែចាំបាច់ មានសមាមាត្រ និងមិនរើសអើង។ ការរឹតត្បិតក៏ចាំបាច់ត្រូវមានកម្រិតសម្រាប់រយៈពេលកំណត់មួយ ហើយវិធានការការពារសុវត្ថិភាពប្រឆាំងនឹងការអនុវត្តហួសកម្រិត ក៏ត្រូវតែធ្វើឡើងជាប្រចាំផងដែរ។

សិទ្ធិមួយចំនួន រួមទាំង សិទ្ធិរស់រានមានជីវិត ការហាមឃាត់មិនឱ្យធ្វើទារុណកម្ម និងការប្រព្រឹត្តមិនត្រឹមត្រូវផ្សេងទៀត និងសិទ្ធិមិនត្រូវបានឃុំខ្លួនដោយបំពាន នៅតែបន្តអនុវត្តនៅក្នុងគ្រប់កាលៈទេសៈ។

ដើម្បីជួយរដ្ឋទាំងឡាយ ក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ កាលពីថ្ងៃចន្ទនេះ ការិយាល័យសិទ្ធិមនុស្ស អ.ស.ប បានចេញសេចក្តីណែនាំគោលនយោបាយថ្មី

https://www.ohchr.org/Documents/Events/EmergencyMeasures_COVID19.pdf ស្ដីពីវិធានការគ្រាអាសន្ន និងវិធានការពិសេស។
អ្នកស្រី ឧត្តមស្នងការ បានមានប្រសាសន៍ថា "មានសេចក្តីរាយការណ៍ជាច្រើន ពីតំបន់ផ្សេងៗគ្នា ដែលថា មន្ត្រីនគរបាល និងកងកំលាំងសន្តិសុខដទៃទៀត បានប្រើកម្លាំងហួសប្រមាណ ហើយនៅពេលខ្លះ វាអាចបណ្តាលឱ្យមានមនុស្សស្លាប់ បង្ខំឱ្យប្រជាជនគោរពតាមបម្រាមបិទការដើរហើរ និងបម្រាមគោចរណ៍។ ការរំលោភបំពានបែបនេះ ជារឿយៗ ត្រូវបានប្រព្រឹត្តទៅលើប្រជាជនក្រីក្រ និងងាយរងគ្រោះបំផុត »។

អ្នកស្រី បាស្សឡេត បានមានប្រសាសន៍ "ការបាញ់ប្រហារ ការឃុំខ្លួន ឬការរំលោភបំពានលើបុគ្គលណាម្នាក់ ចំពោះការបំពានបម្រាមគោចរណ៍ ដោយសារតែពួកគេស្វែងរកអាហារជាចាំបាច់ គឺជាការឆ្លើយតបដែលមិនអាចទទួលយកបាន និងដោយខុសច្បាប់។ ដូច្នេះ វាធ្វើឱ្យមានការលំបាក ឬមានគ្រោះថ្នាក់ដល់ស្ត្រីទៅមន្ទីរពេទ្យ ដើម្បីសម្រាលកូន។ ក្នុងករណីខ្លះ មានមនុស្សស្លាប់ដោយសារតែការអនុវត្តវិធានការមិនសមរម្យ ដែលទំនងជាធ្វើឡើង ដើម្បីជួយសង្គ្រោះពួកគេ"។

"នៅក្នុងប្រទេសមួយចំនួន មនុស្សរាប់ពាន់នាក់ ក៏ត្រូវបានឃុំខ្លួនពីបទរំលោភបម្រាមគោចរណ៍ ដែលជាការអនុវត្តមួយដែលមិនចាំបាច់ និងមិនមានសុវត្ថិភាព។ មន្ទីរឃុំឃាំង និងពន្ធនាគារ គឺជាបរិស្ថានដែលមានហានិភ័យខ្ពស់ ហើយរដ្ឋនានា គួរតែផ្តោតលើការដោះលែងជនជាប់ឃុំណា ដែលអាចត្រូវបានដោះលែងបានដោយសុវត្ថិភាព មិនត្រូវឃុំខ្លួនមនុស្សច្រើនពេកឡើយ"។

ឯកសារណែនាំបានគូសបញ្ជាក់ថា ដូចជាក្នុងពេលធម្មតា មន្ត្រីអនុវត្តច្បាប់ គួរតែប្រកាន់ខ្ជាប់នូវគោលការណ៍នីត្យានុកូលភាពចាំបាច់ សមាមាត្រ និងប្រកបដោយការប្រុងប្រយ័ត្ន។

អ្នកស្រី បាស្សឡេត បានមានប្រសាសន៍ "រដ្ឋទាំងឡាយ គួរតែប្រើកម្លាំងនៅពេលដែលចាំបាច់បំផុត ហើយកម្លាំងដ៏សាហាវ អាចត្រូវបានប្រើតែនៅពេលមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្សតែប៉ុណ្ណោះ"។

វិធានការ និងច្បាប់ដែលត្រូវបានដាក់ឱ្យប្រើនៅក្នុងប្រទេសមួយចំនួន មានសេចក្តីយោងទៅនឹងបទល្មើសដែលបានកំណត់មិនច្បាស់លាស់ ដោយភ្ជាប់ជាមួយនូវការកាត់ទោសដ៏ឃោរឃៅ ដែលធ្វើឱ្យមានការព្រួយបារម្ភថា ពួកគេអាចត្រូវបានប្រើ ដើម្បីបិទមាត់ប្រព័ន្ធផ្សព្វផ្សាយ និងឃុំឃាំងអ្នករិះគន់ និងអ្នកប្រឆាំង។ ទោះបីវិធានការក្នុងការរឹតត្បិតការដើរហើរ និងការជួបប្រជុំ មានលក្ខណៈស្របច្បាប់ក្នុងកាលៈទេសៈបែបនេះក្តី ក៏ជំនឿទុកចិត្ត និងការពិនិត្យពិច័យរបស់សាធារណៈជន គឺសំខាន់ជាការចាំបាច់សម្រាប់វិធានការ និងច្បាប់អនុវត្តមានប្រសិទ្ធភាព។

អ្នកស្រី បាស្សេឡែត បានមានប្រសាសន៍ "វាមានសារៈសំខាន់ណាស់ ក្នុងការប្រឆាំងនឹងព័ត៌មានមិនពិត ប៉ុន្តែការបិទមតិយោបល់ផ្លាស់ប្តូរគំនិត និងព័ត៌មានដោយសេរីមិនត្រឹមតែរំលោភសិទ្ធិប៉ុណ្ណោះទេ ប៉ុន្តែវាធ្វើឱ្យអន្តរាយដល់ជំនឿទុកចិត្តទៀតផង។ ព័ត៌មានមិនពិតអំពីជំងឺកូវីដ-១៩ បង្កហានិភ័យធំធេងដល់មនុស្ស។ ប៉ុន្តែដូចគ្នានឹងសេចក្តីសម្រេចចិត្តគោលនយោបាយមិនល្អផងដែរ"។ "ការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិដូចជាសេរីភាពក្នុងការបញ្ចេញមតិ អាចធ្វើឱ្យអន្តរាយដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងផលប៉ះពាល់ខាងសេដ្ឋកិច្ច សង្គម កើតចេញពីជំងឺនេះ។

សេចក្តីណែនាំនេះ បានបញ្ជាក់យ៉ាងច្បាស់ថា វិធានការនានា មិនត្រឹមតែចាំបាច់ដើម្បីសម្រេចបាននូវគោលដៅសុខភាពសាធារណៈស្របច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏គួរតែជាអភិក្រម "មានការរំខានតិចតួចបំផុត" ដែលត្រូវការ ដើម្បីទទួលបានលទ្ធផលនោះ។

អ្នកស្រី បាស្សេឡែត បានមានប្រសាសន៍ថា "យើងបានឃើញរដ្ឋជាច្រើន អនុម័តវិធានការប្រកបដោយយុត្តិកម្ម សមហេតុផល និងមានកំណត់ពេលវេលា។ ប៉ុន្តែក៏មានករណីគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងផងដែរ ដែលរដ្ឋាភិបាលនានា ហាក់ដូចជាកំពុងប្រើប្រាស់ជំងឺកូវីដ-១៩ ដើម្បីរំលោភសិទ្ធិមនុស្ស ការរឹតត្បិតសេរីភាពជាមូលដ្ឋាន និងលំហពលរដ្ឋ និងការធ្វើឱ្យប៉ះពាល់ដល់នីតិរដ្ឋ"។

អ្នកស្រី បាស្សេឡែត បានមានប្រសាសន៍ថា វិធានការពិសេស ឬស្ថានភាពអាសន្ន គួរតែស្ថិតនៅក្រោមការត្រួតពិនិត្យត្រឹមត្រូវដោយសភា តុលាការ និងសាធារណជន។

អ្នកស្រី បានមានប្រសាសន៍បន្ថែមទៀតថា "វិធានការប្រទេសផ្សេងៗគ្នាស្ថិតក្នុងដំណាក់កាលផ្សេងគ្នានៃការរាតត្បាត។ ប្រទេសមួយចំនួន កំពុងចាប់ផ្តើមចេញពីវិធានការគ្រាអាសន្ន ខណៈពេលដែលប្រទេសផ្សេងទៀតកំពុងពង្រីក ឬពង្រឹងវិធានការដែលបានដាក់ចេញរួចហើយ។ គោលការណ៍ត្រូវតែអនុវត្តតាម គឺថា វិធានការត្រូវតែបានអនុវត្តប្រកបដោយមនុស្សធម៌។ ការដាក់ទោសទណ្ឌចំពោះការបំពានលើវិធានការទាំងនេះ គួរតែមានលក្ខណៈសមាមាត្រ និងមិនត្រូវបានធ្វើដោយបំពាន ឬរើសអើងឡើយ"។

អ្នកស្រី បានមានប្រសាសន៍ថា "ដោយសារវិបត្តិនេះមានលក្ខណៈពិសេស វាច្បាស់ណាស់ថា រដ្ឋទាំងឡាយ ត្រូវការអំណាចបន្ថែម ដើម្បីដោះស្រាយ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើនីតិរដ្ឋមិនត្រូវបានគាំទ្រ ដូច្នេះ គ្រោះអាសន្នផ្នែកសុខភាពសាធារណៈនឹងក្លាយជាគ្រោះមហន្តរាយដល់សិទ្ធិមនុស្សជាមួយនឹងផលប៉ះពាល់អវិជ្ជមានដែលអាចធ្វើឱ្យជំងឺរាតត្បាតរីករាលដាលបានដ៏យូរ"។

**ចប់**

សូមមើលផងដែរ សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ដោយគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ស្តីពីការដកហូតសិទ្ធិមួយចំនួន ពីកតិកាសញ្ញា ICCPR ទាក់ទងនឹងជំងឺកូវីដ១៩ ។

*សម្រាប់ព័ត៌មានបន្ថែម និងការស្នើសុំព័ត៌មាន សូមទាក់ទង លោក រ៉ូភើត ខូលវិល (Rupert Colville) តាមរយៈទូរស័ព្ទលេខ៖ + ៤១ ២២ ៩១៧ ៩៧៦៧ ឬអ៊ីម៉ែល rcolville@ohchr.org ឬលោក ចេរមី ឡូរិនស៍ (Jeremy Laurence) តាមរយៈទូរស័ព្ទលេខ៖ + ៤១ ២២ ៩១៧ ៩៣៨៣ ឬអ៊ីម៉ែល jlaurence@ohchr.org ឬអ្នកស្រី លីហ្ស ស្រូសហ្សែលល៍ (Liz Throssell) តាមរយៈទូរស័ព្ទលេខ៖ + ៤១ ២២ ៩១៧ ៩២៩៦ ឬអ៊ីម៉ែល ethrossell@ohchr.org ឬលោកស្រី ម៉ារតា ហ៊ូរតាដូ (Marta Hurtado) តាមរយៈទូរស័ព្ទលេខ៖ + ៤១ ២២ ៩១៧ ៩៤៦៦ ឬអ៊ីម៉ែល mhurtado@ohchr.org*

***ថែក និងស៊ែរ - ទ្វីតធឺ ៖ @UNHumanRights និងហ្វេសប៊ុក៖ unitednationshumanrights***